**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

**មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់**

**និងសុរិយោដី ខេត្តកំពង់ធំ**

លេខ:២១១/២៦.ដនសស/ កធ ស.ជ.ណ

ថ្ងៃអង្គារ ១៤កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

កំពង់ធំ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង

## ស្តីពី ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

**យោង:**
- តាមអនុក្រឹត្យលេខៈ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- អនុក្រឹត្យលេខៈ ១២២ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៧ និងមាត្រា ១១ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- របាយការណ៍លេខ០៣២ដនស/អរប/របា ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៦ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្តីពីកិច្ចប្រជុំអន្តរក្រសួងពិភាក្សាពីការផ្តល់សេវាសាធារណៈលើវិស័យសុរិយោដី និងសំណង់ ជូនប្រជាជន

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ធំ សូមជូនដំណឹងដល់សាធារណៈជនព្រមទាំងគ្រប់មន្ទីរអង្គភាព និងគ្រប់ស្ថាប័ន ឬភ្នាក់ងារហិរញ្ញវត្ថុដែលមានការពាក់ព័ន្ធ និងក្បាលដីទាំងអស់ដែលស្ថិតនៅក្នុងតំបន់វិនិច្ឆ័យនៃ **ភូមិគគរ និងភូមិត្រើរ ឃុំដូង ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ** ឱ្យបានជ្រាបថាៈ ដើម្បីអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យយោងខាងលើគណៈកម្មការរដ្ឋបាលនឹងធ្វើការបិទផ្សាយជាសាធារណៈនូវឯកសារសុរិយោដីរួមមានប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដីដែលក្រុមការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធបានធ្វើការវាស់វែង និងប្រមូលទិន្នន័យបានរួចរាល់កន្លងមក។

ហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណៈជនអ្នកកាន់កាប់ដី និងអង្គភាពទាំងអស់ ចូលរួមពិនិត្យលើទិន្នន័យក្បាលដីដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ ឬខុសឆ្គងដែលត្រូវកែតម្រូវ ឬជំទាស់លើទិន្នន័យទាំងនោះក្នុងរយៈពេល ១៥ថ្ងៃ (រាប់បញ្ចូលទាំងថ្ងៃឈប់សំរាក)គិតចាប់ពីថ្ងៃទី **៣១** ខែ **កក្កដា** ឆ្នាំ **២០២៦** រហូតដល់ថ្ងៃទី **១៤** ខែ **សីហា** ឆ្នាំ **២០២៦** ជាកំហិតស្ថិតនៅក្នុងបរិវេណ **វត្តដូង** ស្ថិតនៅ **ភូមិត្រើរ ឃុំដូង ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ។**

ផុតកំណត់ខាងលើ គណៈកម្មការរដ្ឋបាល សន្មត់ថាទិន្នន័យដែលបានបើកចំហរជូនពិនិត្យជាសាធារណៈនេះមានភាពត្រឹមត្រូវហើយមិនអាចជំទាស់ ឬតវ៉ានៅពេលក្រោយទៀតបានឡើយ។

**សូមបញ្ជាក់ថា:** គណៈកម្មការរដ្ឋបាល នឹងដាក់ទីតាំងជាបណ្តោះអាសន្ននៅកន្លែងបិទផ្សាយខាងលើ ដើម្បីរង់ចាំទទួលពិគ្រោះ និងផ្តល់យោបល់ដល់អ្នកដែលមានចម្ងល់ បញ្ហា និងសំណូមពរ។

**ប្រធានមន្ទីរ**

**អ៊ឹម សុខីណា**

**ចម្លងជូន:**

*-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

*-រដ្ឋបាលខេត្តកំពង់ធំ*

*"ដើម្បីគោរពជូនជ្រាប"*

*-រដ្ឋបាល ស្រុកប្រាសាទបល្ល័ង្ក*

*-គ្រប់ធនាគារ និងអង្គភាពហិរញ្ញវត្ថុ "ដើម្បីជ្រាបជាព័ត៌មាន និងជួយផ្សព្វផ្សាយ"*

*-ឯកសារកាលប្បវត្តិ*